# និមិត្តរូបភ្នំកៃលាសក្នុងពិធីកោរជុក

នៅក្នុងទេពកថា គេយល់ថាភ្នំកៃលាសជាឋានទេព ដែលមានព្រះឥសូរជាអាទិ។ កស្តុតាងនេះ ក្នុងសិល្បៈខ្មែរគេឃើញច្បាស់ត្រង់អន្ទើក្រុងរាពណ៍អង្រួនភ្នំកៃលាសឆ្លាក់តាមប្រាសាទនានាដូចជា ចម្លាក់លើហោជាងប្រាសាទបន្ទាយស្រី លើជញ្ជាំងប្រាសាទអង្គរវត្ត និងផ្តែរមួយនៅសារមន្ទីរជាតិជាដើម។[១] ចម្លាក់ទាំងនោះ គេឃើញមានវត្តមានព្រះឥសូរជានិច្ច។ រីឯក្នុងទំនៀមកោរជុក ឬកោរកំប៉ាយ[២] អ្នកស្រាវជ្រាវយល់ថា "រានកោរ" (ស្រុកខ្លះហៅថារានម៉ា) គឺជានិមិត្តរូបភ្នំកៃលាស។[៣] តាមការសង្កេត គេតែងសង់រាននេះយ៉ាងផ្ចិតផ្ចង់ ខ្ពស់ត្រដែត និងតុបតែងលម្អយ៉ាងវិចិត្រក្រៃលែងគួរឱ្យពិចារណា។

ដូចបានបញ្ជាក់ខ្ញីមកខាងលើ ការសង់រានកោរត្រូវធ្វើឱ្យផ្ចិតផ្ចង់ ហើយការសង់រាននេះត្រូវចំណាយពេលយូរច្រើនថ្ងៃ ទុកត្រៀមមុននឹងដល់ថ្ងៃប្រារព្ធពិធី។ ការសង់ត្រូវចំណាយពេលយូរ ព្រោះគេត្រូវធ្វើឱ្យជាប់មាំល្អផង និងត្រូវធ្វើឱ្យត្រឹមត្រូវតាមក្បួន ព្រមទាំងត្រូវមានការចាក់ចេកតុបតែងតាមសសរ និងផ្នែកផ្សេងៗជាច្រើនផង។ គេតែងសង់ឱ្យមានកំពូលខ្ពស់ ឬសង់ជាប់ពីផ្ទះ និងធ្វើឱ្យមានកន្លែងដើរប្រទក្សិណផងក៏មាន។[៤] មិនតែប៉ុណ្ណោះ រានកោរនោះតែងសង់ឱ្យមានរាងជាថ្នាក់ៗ។ ថ្នាក់ក្រោម ជាកន្លែងដើរប្រទក្សិណ និងសាមីពិធីអង្គុយធ្វើកិច្ច ព័ទ្ធដោយបង្កាន់ដៃកម្ពស់ប្រហែលកន្ទះម៉ែត្រ។ ចំណែកថ្នាក់លើ ជួនគេសង់ឱ្យមានមុខបួនបែរទៅគ្រប់ទិសធំទាំងបួន ឬសង់ឱ្យមានមុខតែមួយបែរទៅទិសខាងកើត។ ក្នុងបរិបទដែលខ្មែរគោរពពុទ្ធសាសនាដូចសព្វថ្ងៃ មុខងារនៃថ្នាក់ទី២ គឺសម្រាប់ចងព្រះបត់ តម្កល់គ្រឿងសក្ការៈ និងព្រះសង្ឃគង់ធ្វើកិច្ច។

---

[១] សូមអានអត្ថបទ "ក្រុងរាពណ៍ចាប់អង្រួនភ្នំកៃលាស" ដោយ រ៉ា សុវណ្ណរដ្ឋ លើគំណ http://www.yosothor.org/publications/khmer-renaissance/chapter-four/Ravarana_Kailasa.html

[២] ខៀវ ច័ន្ទ និង អ៊ឹម សុខរិទ្ធី ២០១៥: ៣១-៣២

[៣] Adhémard Leclère 1901: 212, អាំង ជូលាន ព្រាប ចាន់ម៉ារ៉ា ស៊ុន ចាន់ដឹប ២០០៧: ១៩ និង ព្រាប ចាន់ម៉ារ៉ា ២០០៥: ៨៤

[៤] ស៊ុន ចាន់ដឹប ២០០៧: ៣០៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាទូទៅនៃរានកោរ តែងភ្ជាប់ទៅដី ឬភ្ជាប់ទៅផ្ទះដោយស្ពានតូចមួយ។ ក្នុងពិធីកោរជុក គេធ្វើកិច្ចសំខាន់ពីរនៅលើរានកោរនេះ។ ឧទាហរណ៍មួយនៃពិធីកោរជុកនៅភូមិត្នោតជ្រុំ ខេត្តសៀមរាប លោកអាចារ្យនាំក្មេងដែលត្រូវផ្កាច់ជុកក្នុងពេលដ៏ខ្ញីខាងមុខមកធ្វើធ្មេញនៅលើរានកោរ។ បន្ទាប់មក ទើបព្រះសង្ឃនិមន្តធ្វើកិច្ចផ្កាច់ជុកជាស្ថាពរ។ ប៉ុន្តែនៅភូមិខ្លះទៀត គេប្រើរានកោរសម្រាប់តែកិច្ចផ្កាច់ជុកតែម្តងគត់។ ដោយឡែកព្រះសង្ឃដែលមាននាទីក្នុងពិធីនេះពុំប្លែកអ្វីឡើយ ដ្បិតខ្មែរគោរពពុទ្ធសាសនា ហើយជាទូទៅមានបួនអង្គផង។ តាមដែលគេធ្លាប់ឃើញ ព្រះសង្ឃហាក់មាននាទីផ្កាច់ជុក ដោយពុំបានកោរសម្អាតបញ្ចប់ទេ ជួនកាលទៀតគ្រាន់តែធ្វើកាយវិការឧបកិច្ចប៉ុណ្ណោះ។ ប៉ុន្តែនាទីសំខាន់សម្រាប់ព្រះសង្ឃ គឺយកទឹកស្រោចលើក្បាលក្មេង ហើយជួនកាលយកបាត្រដាក់ទឹកស្រោចផ្ទាល់ ឬជួនកាលយកស័ង្ខមកប្រើដូចនៅក្នុងពិធីព្រាហ្មណ៍ដែរ។ ប្រការត្រង់នេះ ក្នុងទំនៀមរាជវង្សគេចាត់ទុកថាដូចជាព្រះគង្គាដែលធ្លាក់ចុះពីលើមេឃ ហើយទាល់តែព្រះឥសូរយកព្រះកេសមកទ្រសិន ដើម្បីកុំឱ្យទម្ងន់ទឹកនោះធ្វើឱ្យស្រុតផែនដី មុននឹងហូរកើតជាទន្លេ។[៥] រីឯក្នុងគំនូររឿងរាមកេរ្តិ៍នៅវត្តរាជបូព៌ ខេត្តសៀមរាប ត្រង់ផ្ទាំងមួយដែលនិយាយពីពិធីកោរសក់អង្គទ គេឃើញច្បាស់ថាឥសីជាអ្នកធ្វើកិច្ចផ្កាច់ជុក។[៦]

យ៉ាងណាក៏ដោយ ដូចបានបញ្ជាក់ខ្ញីខាងដើមថា រានកោរតែងធ្វើឱ្យខ្ពស់ និងដាច់ពីផ្ទះ។ មិនតែប៉ុណ្ណោះនៅរានកោរនេះ គេមិនអនុញ្ញាតឱ្យក្មេង ឬមនុស្សម្នាឡើងលេងផ្តេសផ្តាសឡើយ ហើយដើម្បីឡើងដល់រានកោរនោះ តែងមានអាចារ្យជាអ្នកដឹកដៃនាំមុខ។ កិច្ចត្រង់នេះ គេសង្កេតឃើញអាចារ្យកាន់ដងថ្លិចមួយ ភ្ជាប់ដោយទៀនអុជបំភ្លឺ ដង្ហែប្រទក្សិណ៣ជុំ មុននឹងផ្តើមធ្វើកិច្ចកាត់ផ្កាច់ជុកជាស្ថាពរ។ សរុបខ្ញីមកទិដ្ឋភាពខាងលើហាក់ស្តែងឱ្យឃើញច្បាស់ថា រានកោរជាភ្នំកៃលាសដែលជាឋានទេព តែងស្ថិតនៅខ្ពស់ត្រដែត ដាច់ពីទីមនុស្សរស់នៅ ហើយដើម្បីឡើងដល់ទីនោះពុំមែនជារឿងងាយទេ៕

[៥] អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប ២០០៧: ១៩ និង អ៊ូ គង្គា ២០១៣: ៥៦

[៦] សូមអាន "កោរជុក" ដោយលោក ថាន់ មនោមយិទ្ធិ នៅលើតំណ https://ams.com.kh/khmercivilization/detail/493

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព



រូបលេខ២១ ពនកោរនៅតំបន់អង្គរ

(ប្រភព៖ អាជ្ញាធរជាតិអប្សរា)



រូបលេខ២១ ពនកោរនៅភូមិត្នោតជ្រុំ ខេត្តសៀមរាប





រូបលេខ២៣ និងលេខ២៤ ការតុបតែងលម្អ និងគ្រឿងសក្ការៈតម្កល់ក្នុងពនកោរ





រូបលេខ២៥ និងលេខ២៦ អាចារ្យធ្វើកិច្ចនៅលើពនកោរ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៧ អាចារ្យនាំសាមីពិធីឡើងលើរានកោរ (ប្រភព៖ សុខ កែវណ្ណារ៉ា)



រូបលេខ៨ អាចារ្យកាន់ឈើថ្លិចនាំសាមីពិធីដើរប្រទក្សិណនៅលើរានកោរ



រូបលេខ៩ អាចារ្យធ្វើកិច្ចធ្វើធ្មេញ



រូបលេខ១០ ព្រះសង្ឃគង់លើរានកោរឧបកិច្ចផ្តាច់ជុក



រូបលេខ១១ កិច្ចផ្តាច់ជុកជាស្ថាពរ



រូបលេខ១២ ព្រះសង្ឃស្រោចទឹកស័ង្ខក្នុងកិច្ចផ្តាច់ជុក

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ខៀវ ច័ន្ទ និង អ៊ឹម សុខរិទ្ធី

២០១៥, "កោរជុកនៅអង្គរវត្ត" *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, យសោធរ, ភ្នំពេញ*

ថាន់ មនោមយិទ្ធិ

២០២០ "កោរជុក" លើគំហើ https://ams.com.kh/khmercivilization/detail/493

ព្រាប ចាន់ម៉ារ៉ា

២០០៥, "ទោះជាយ៉ាងណាក៏ត្រូវមានសោភ័ណភាព", *ខ្មែរ*, លេខ២៦, FOKCI, ទំ. ៨៣-៩១

រ៉ា សុវណ្ណរដ្ឋ

២០១៩ "ក្រុងរាពណ៍ចាប់លើកអង្រួនភ្នំកៃលាស" លើគំហើ
http://www.yosothor.org/publications/khmer-renaissance/chapter-four/Ravarana_Kailasa.html

ស៊ុន ចាន់ដឹប

២០០៧, "ពិធីកោរជុកនៅខេត្តកំពង់ចាម៖ ដង្ហើមចុងក្រោយត្រូវរស់?" *ខ្មែរ*, លេខ២៨, FOKCI, ទំ. ៣០៧-៣១៣

អ៊ូ គង្គា

២០១៣, *ព្រះគង្គា*, នគរវត្ត, ភ្នំពេញ

អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, និង ស៊ុន ចាន់ដឹប

២០០៧, *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ*, ហនុមានទេសចរណ៍, ភ្នំពេញ

Adhémard Leclère

1901, "Le Cûlâ-Kantana-Mangala ou La fête de la coupe de la Houppe d'un prince royal à Phnôm-Pénh, le 16 mai 1901", *BEFEO,* Tome I, p. 208-230

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត